# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ ៖ ថ្ងៃចន្ទ ៧កើត ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
  ត្រូវនិងថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០២៤
- ថ្នាក់កម្រិត ៖ មធ្យម
- មុខវិជ្ជា ៖ ភាសាខ្មែរ
- ប្រធានបទ ៖ សមត្ថភាពគូស និង សរសេរ
- សកម្មភាពគោល ៖ ល្បែង
- ចំណងជើងមេរៀន ៖ គូសតាមស្នាមចុចរូបភាពកង់ និងផាត់ពណ៌
- រយៈពេល ៖ ៣០ នាទី

## I. វត្ថុបំណង

- វិជ្ជាសម្បទា ៖ កុមារប្រាប់ពីរបៀបគូស និងគូសតាមស្នាមចុចរូបភាព កង់ និងផាត់ពណ៌ បានត្រឹមត្រូវតាមរយៈការណែនាំរបស់គ្រូ។
- បំណិនសម្បទា ៖ កុមារកំណត់បានពីរបៀបគូស និងគូសតាមស្នាមចុចរូបភាពកង់ និងផាត់ពណ៌បានត្រឹមត្រូវតាមរយៈការអនុវត្តន៍ផ្ទាល់។
- ចរិយាសម្បទា ៖ បណ្តុះភាពឈ្លាសវៃ រហ័សរហួន ក្នុងការអនុវត្តន៍កិច្ចការបានត្រឹមត្រូវ។

## II. សម្ភារៈឧបទេស និងការរៀបចំ

- សម្ភារៈឧបទេស
  - សម្ភារៈគ្រូ ៖ ផ្ទាំងរូបភាពកង់ សន្លឹកកិច្ចការ ខ្មៅដៃ
  - សម្ភារៈកុមារ ៖ សន្លឹកកិច្ចការ ខ្មៅដៃ
- ការរៀបចំ
  - ទីកន្លែង ៖ ក្នុងថ្នាក់រៀន
  - ការរៀបចំ ៖ អង្គុយជារៀងអក្សរ អ៊ុយ (U)
- គោលវិធី ៖ សិស្សមជ្ឈមណ្ឌល

## III. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -តើកូនៗមកជុំគ្នាហើយឬនៅកូន ?<br>-តើពេលចេញលេងមុននេះកូនៗមានបានលេងដីដែរ ឬ ទេ ?<br>-តើកូនល្អគេអង្គុយយ៉ាងមិចកូន ?<br>-ឥឡូវកូនក្រោកឈរឡើងច្រៀងបទ ៖ កង្កែបចេញពីសាលាទាំងអស់គ្នាណា | ជំហានទី១<br>*លំនឹងថ្នាក់<br>-វត្តមាន/អវត្តមាន<br>-អនាម័យ<br><br>-សណ្តាប់ធ្នាប់<br>-ការប្រមូលអារម្មណ៍<br><br>ជំហានទី២ | -ជម្រាបអ្នកគ្រូ មកជុំគ្នាហើយ<br>-ជម្រាបអ្នកគ្រូអត់បានលេងទេ<br><br>-ជម្រាបអ្នកគ្រូ គេអង្គុយដាក់ដៃលើភ្លៅ<br>-ក្រោកឈរច្រៀងទាំងអស់គ្នា |

| | | |
|---|---|---|
| -តើកាលពីសប្តាហ៍មុនអ្នកគ្រូបានបង្រៀនភាសាខ្មែរអ្វីដល់កូន? | *ត្រួតពិនិត្យមេរៀនចាស់<br>-ភាសាខ្មែរ៖ល្បែងគូសតាមស្នាមចុច អក្សរ ឡ និងផាត់ពណ៌រូបឡាន | -កុមារឆ្លើយ |
| -តើនៅពេលទៅសាលាបងៗរបស់កូនគាត់ជិះអ្វីដែរ? | *ទំនាក់ទំនងមេរៀនថ្មី<br>-ជិះកង់ ម៉ូតូ.... | -ជិះកង់ ម៉ូតូ.... |
| | ជំហានទី៣<br>*មេរៀនថ្មី៖ភាសាខ្មែរៈល្បែងគូសតាមស្នាមចុចរូបភាពកង់ និងផាត់ពណ៌ | |
| -ថ្ងៃនេះអ្នកគ្រូមានមេរៀនថ្មីមកបង្រៀនកូនគឺ ភាសាខ្មែរ ៖ ល្បែងគូសតាមស្នាមចុចរូបភាពកង់ និងផាត់ពណ៌ | -ប្រាប់ចំណងជើងមេរៀនថ្មី | -ស្តាប់ |
| -កូនៗថាតាមអ្នកគ្រូទាំងអស់គ្នាណា | -អានចំណងជើងមេរៀន | -កុមារអានតាមគ្រូ |
| -កូនបិទភ្នែកអ្នកគ្រូមានរបស់ចង់ឲ្យកូនមើលណាៈនេះនែតើជារូបអ្វីកូន? | -បង្ហាញសម្ភារៈ៖រូបភាពកង់ | -មើល ឆ្លើយ |
| -ចា! ដើម្បីបានរូបកង់នេះគឺយើងត្រូវ យកខ្មៅដៃគូសតាមស្នាមចុចៗរូបភាពកង់គូសយ៉ាងណាឲ្យចំតាមស្នាមចុចៗនេះកុំឲ្យចេញក្រៅ បន្ទាប់មកផាត់ពណ៌នៅលើពាក្យកង់ជាការស្រេច | -ណែនាំពីរបៀបអនុវត្តន៍ | -ស្តាប់ |
| -កូនណាក្លាហានអាចឡើងមកនិយាយឡើងវិញ និងធ្វើសាកល្បងឲ្យមិត្តភក្តិយើងមើលបានកូន | -ឲ្យកុមាររៀបរាប់ពីរបៀបអនុវត្តន៍ឡើងវិញ និងធ្វើសាកល្បង | -កុមារឡើងសាកល្បង |
| -កូនតំណាងក្រុមឡើងមកយកសម្ភារៈចែកឲ្យមិត្តភក្តិ | -ចែកសម្ភារៈឲ្យកុមារជាបុគ្គល | -កុមារម្នាក់ទទួលសម្ភារៈ |
| -កូនៗចាប់ផ្តើមអនុវត្តន៍បានហើយណា | -អនុវត្តន៍ជាបុគ្គល | -អនុវត្តន៍ជាបុគ្គល |
| -កូនៗត្រូវធ្វើដោយយកចិត្តទុកដាក់ និងមានបម្រុងប្រយ័ត្ន ដើម្បីឲ្យកិច្ចការកូនបានល្អនិងត្រឹមត្រូវណា | -គ្រូដើរសម្របសម្រួល និងជួយសិស្សធ្វើមិនទាន់បានល្អ | -មើល ស្តាប់ |
| -អ្នកគ្រូឃើញថាកូនៗធ្វើបានល្អច្រើន ហើយតែក៏នៅមានកូនខ្លះនៅមិនទាន់បានល្អនៅឡើយ ចំពោះកូនដែលធ្វើមិនទាន់បានល្អកូនត្រូវធ្វើឲ្យបានល្អជាងនេះនៅពេលក្រោយណា | -គ្រូបិទលទ្ធផលនៅលើក្តារខៀន៖<br>+ផ្ទៀងផ្ទាត់ លទ្ធផលល្អ និងមិនទាន់បានល្អ<br>+ប្រាប់ពីឈ្មោះសន្លឹកកិច្ចការកុមារដែលត្រូវកែលម្អ | -មើល សាប់ |
| | ជំហានទី៤<br>*ពង្រឹងចំណេះដឹង | |
| -តើមុននេះអ្នកគ្រូបានបង្រៀនភាសាខ្មែរអ្វីដល់កូនៗទាំងអស់គ្នា? | -ភាសាខ្មែរ៖ល្បែងគូសតាមស្នាមចុចរូបភាពកង់ និងផាត់ពណ៌ | -កុមារម្នាក់ឆ្លើយ |
| -កូនណាអាចឡើងមកធ្វើឡើងវិញឲ្យមិត្ត | -អនុវត្តន៍ឡើងវិញ ១ឬ២នាក់ | -អនុវត្តន៍ឡើងវិញ១ឬ២នាក់ |

| | | |
|---|---|---|
| ភក្តិយើងមើលម្តងទៀតបានកូន<br><br>-អ្នកគ្រូសប្បាយចិត្តណាស់ដែលឃើញកូនៗមានភាពវៃឆ្លាត និងយកចិត្តទុកដាក់នៅពេលរៀនសូត្រអញ្ចឹង<br><br>-ពេលត្រឡប់ទៅផ្ទះវិញកូនកុំភ្លេចប្រាប់ប៉ាម៉ាក់ថាកូនបានរៀន ភាសាខ្មែរៈល្បែងគូសតាមស្នាមចុចរូបភាពកង់ និងផាត់ពណ៌ផងណាកូន | ជំហានទី៥<br>*ការសរសើរ និងលើកទឹកចិត្ត<br>-កុមារមានភាពសប្បាយរីករាយ<br><br>*បណ្តាំផ្ញើ និងកិច្ចការផ្ទះ<br>-កុមារស្តាប់ដោយយកចិត្តទុកដាក់ | -សប្បាយចិត្ត<br><br>-កុមារស្តាប់ដោយយកចិត្តទុកដាក់ |

មតិយោបល់.......................................
.........................................................
.........................................................
.........................................................។

ថ្ងៃចន្ទ ទី ០៩ ខែ កញ្ញា ឆ្នាំ ២០២៤
គ្រូប្រចាំថ្នាក់

បានពិនិយត្យត្រឹមត្រូវ
ថ្ងៃ..................ទី...........ខែ..................ឆ្នាំ២០២៤
នាយិកាសាលា

ឈាន សុខមឿន